Sub-dec
Foreign Trade

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា　　　　ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៩៤ អនក្រ.បក

[illegible]
ចូលថ្ងៃទី 13 ខែ 9 ឆ្នាំ 2002 ម៉ោង ____ នាទី
បញ្ជីលេខ 8245

## អនុក្រឹត្យ
## ស្តីពី
## បែបបទនិងលក្ខខណ្ឌនៃការអនុញ្ញាតឱ្យជនបរទេស ជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការ ប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យ វេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០០/០៣៩ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈគ្រូពេទ្យ .
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៩ ខែ សីហា ឆ្នាំ២០០២



ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤១ មហាវិថីសហព័ន្ធរុស្ស៊ី ទូរសារ : ០២៣ ៨៨០ ៦២៤ ទូរស័ព្ទ : ០១៦ ៨១៤ ០០៦ / ០១២ ៨០៤ ៤៤២

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់បែបបទនិងល័ក្ខខ័ណ្ឌនៃការអនុញ្ញាត ឱ្យជនបរទេសដែលជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

អាចអនុញ្ញាតឱ្យជនបរទេសដែលជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវឯកជនក្នុងព្រះរាជាណាចក្រកម្ពុជាបាន លើកលែងតែបើក ឬប្រកបវិជ្ជាជីវៈជាទ្រង់ទ្រាយ បន្ទប់ពិគ្រោះព្យាបាលជំងឺ។ ជនបរទេសទាំងនោះ ត្រូវមានលក្ខណសម្បត្តិ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូច ខាងក្រោមនេះ៖

១. មកពីបណ្តាប្រទេសដែលជាសមាជិករបស់អង្គការសុខភាពពិភពលោក

២. មានបទពិសោធន៍ក្នុងវិជ្ជាជីវសុខាភិបាលយ៉ាងតិច៥ឆ្នាំ

៣. មានចុះឈ្មោះដែលនៅមានសុពលភាពនៅឡើយ ក្នុងបញ្ជីសមាជិកគណៈវិជ្ជាជីវសុខាភិបាលនៃប្រទេសសាមី ឬ ត្រូវបានក្រសួងសុខាភិបាល-ស្ថានទូតប្រទេសសាមីទទួលស្គាល់

៤. មានសញ្ញាប័ត្រជំនាញឯកទេសខ្ពស់ ទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ចនៃប្រទេសសាមី

៥. មានកាយសម្បទា និងសុខភាពគ្រប់គ្រាន់អាចបំពេញការងារបាន

៦. ត្រូវគោរពទំនៀមទម្លាប់ប្រពៃណីខ្មែរ

៧. ត្រូវបានចុះឈ្មោះបន្ថែមក្នុងបញ្ជីគណៈវិជ្ជាជីវសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

៨. មិនដែលត្រូវបានផ្តន្ទាទោសជាមជ្ឈិម ឬឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬផ្តន្ទាទោសជាបទរដ្ឋបាល ដូចជាការលុបឈ្មោះចោល ឬការបញ្ឈប់ពីមុខងារ ការដកហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ ។ មិនត្រូវមានធនក្ស័យផ្ទាល់ខ្លួន ដែលបានប្រកាសដោយតុលាការ ។

ក្រសួងសុខាភិបាលមានឆន្ទានុសិទ្ធិក្នុងការមិនអនុញ្ញាតឱ្យជនបរទេសដែលជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា ទោះជាអ្នកនោះឬអ្នកទាំងអស់នោះបាន បំពេញ និងបានគោរពទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងអនុក្រឹត្យនេះក៏ដោយ ។

40



41

## ជំពូកទី២
## បែបបទរដ្ឋបាល

មាត្រា ៣.-

ជនបរទេស ជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដែលមានបំណងប្រកបវិជ្ជាជីវៈឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវដាក់ពាក្យសុំមកក្រសួងសុខាភិបាល មានសំណុំលិខិតដូចខាងក្រោមនេះ :

១. លិខិតឆ្លងដែនត្រឹមត្រូវ ដែលមានទិដ្ឋាការប្រភេទអឺ(E) មានសុពលភាព សមស្របទៅនឹងរយៈពេលនៃការអនុវត្តការងារ

២. ជីវប្រវត្តិសង្ខេប

៣. មានប័ណ្ណការងារ និងសៀវភៅការងារ ដែលចេញដោយក្រសួងទទួលបន្ទុកវិស័យការងារ ស្របតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចសន្យាការងារដែលមានថេរៈវេលាកំណត់ជាលាយល័ក្ខណ៍អក្សរជាភាសាខ្មែរ បារាំង ឬអង់គ្លេស ។

៤. លិខិតថ្កោលទោសចេញដោយក្រសួងមានសមត្ថកិច្ចរបស់ប្រទេសសាមី ជាច្បាប់ដើម ដោយមានទីត្យានុកូលកម្មត្រឹមត្រូវ ពីអាជ្ញាធរពាក់ព័ន្ធរបស់ប្រទេសសាមី និងបកប្រែជាភាសាខ្មែរដោយមានការបញ្ជាក់ ពីក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

៥. និងបណ្ដាឯកសារដែលបានបំពេញតាមល័ក្ខខ័ណ្ឌដែលចែងក្នុងមាត្រា២ខាងលើនេះ។

## ជំពូកទី ៣
## លក្ខខ័ណ្ឌនៃការប្រកបវិជ្ជាជីវៈ

មាត្រា ៤.-

ជនបរទេស ជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ កំពុងបំពេញបេសកកម្មស្របច្បាប់ នៅតាមមន្ទីរពេទ្យសាធារណៈ ឬនៅមន្ទីរពេទ្យអង្គការនានា និង បម្រើឱ្យអង្គការអន្តរជាតិ អង្គការ ក្រៅរដ្ឋាភិបាល គ្មានសិទ្ធិប្រកបវិជ្ជាជីវៈឯកជន នៅព្រះរាជាណាចក្រកម្ពុជាទេ ។

មាត្រា ៥.-

ជនបរទេសដែលប្រកបវិជ្ជាជីវៈ នៅក្នុងមន្ទីរសម្រាកព្យាបាល មន្ទីរពហុព្យាបាល និងមន្ទីរសម្ភពឯកជន ត្រូវអនុវត្តទៅតាមប្រកាសរបស់ក្រសួងសុខាភិបាល ស្ដីពីបែបបទ និងល័ក្ខខ័ណ្ឌបច្ចេកទេសក្នុងការសុំ បើក ឬ បិទ ស៊ុំកែទ្រង់ទ្រាយ ប្ដូរទីតាំង នៃសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន។



41

សេវាកម្មនេះ អាចឱ្យប្រើប្រាស់បុគ្គលិកជាជនបរទេស សមស្របតាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យការងារនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៦.-

មិនអនុញ្ញាតឱ្យ ម្ចាស់សេវាមន្ទីរសម្រាកព្យាបាល មន្ទីរពហុព្យាបាល មន្ទីរសម្ភព ផ្ទេរការងារបុគ្គលិកជាជនបរទេស ដែលបម្រើការងារក្នុងមន្ទីរសម្រាកព្យាបាល មន្ទីរពហុព្យាបាល មន្ទីរសម្ភព របស់ខ្លួនទៅឱ្យជនបរទេសណាមួយទៀត ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

មាត្រា ៧.-

ជនបរទេសដែលជាម្ចាស់សេវា ត្រូវមានវត្តមានក្នុងសេវារបស់ខ្លួន ក្នុងករណីអវត្តមានលើសពីដប់ថ្ងៃ (១០ថ្ងៃ) ម្ចាស់សេវា ត្រូវជូនពត៌មានមកក្រសួងសុខាភិបាល ។

## ជំពូកទី ៤
## ការវិនិយោគមន្ទីរពហុព្យាបាលខ្នាតអន្តរជាតិ

មាត្រា ៨.-

ការវិនិយោគមន្ទីរសម្រាកព្យាបាល មន្ទីរពហុព្យាបាល មន្ទីរព្យាបាលខ្នាតអន្តរជាតិ ត្រូវគោរព តាមច្បាប់វិនិយោគ និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៩.-

អ្នកវិនិយោគត្រូវបំពេញតាមល័ក្ខខ័ណ្ឌស្តង់ដារវេជ្ជសាស្ត្រ កំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

មាត្រា ១០.-

អ្នកវិនិយោគត្រូវបានអនុញ្ញាតឱ្យជួលនិយោជិតបរទេស ជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដែលបានបំពេញលក្ខណសម្បត្តិ និងល័ក្ខខ័ណ្ឌដូចមានចែងក្នុងជំពូកទី១ ទី២ ទី៣ នៃអនុក្រឹត្យនេះ។

មាត្រា ១១.-

អ្នកវិនិយោគមានកាតព្វកិច្ច ធ្វើការបណ្តុះបណ្តាលជាប្រចាំ និង សមស្របជូននិយោជិតខ្មែរតាមកម្មវិធីរបស់ក្រសួងសុខាភិបាល ។

មាត្រា ១២.-

ក្នុងករណីអ្នកវិនិយោគមានបំណងចង់បញ្ចប់សកម្មភាពវិនិយោគរបស់ខ្លួន នៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកវិនិយោគនោះត្រូវដាក់ពាក្យសុំមកក្រសួងសុខាភិបាល ដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់ ។



42

មាត្រា ១៣.-

ក្នុងករណីអ្នកវិនិយោគរំលោភ ឬមិនអនុវត្តតាមល័ក្ខខ័ណ្ឌកំណត់ទាំងឡាយនៃអនុក្រឹត្យនេះ ក្រសួងសុខាភិបាល មានសិទ្ធិផ្អាកសកម្មភាពវិនិយោគជាបណ្ដោះអាសន្ន និងកសាងសំណុំបែបបទទៅតុលាការ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

មាត្រា ១៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១៥

-ឯកសារ-កាលប្បវត្តិ